**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ១៤៩ សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការអនុញ្ញាតឱ្យប្រើប្រាស់កម្មវិធីកាត់បន្ថយអត្រាពន្ធគយ នៃផ្នែកទីបួនរបស់បញ្ជីដកចេញបណ្តោះអាសន្ន

.........................

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹតលេខ នស/រកត/០៧០៤/១១៧ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញភាពចាំបាច់ក្នុងការបំពេញកាតព្វកិច្ច ដែលមានចែងនៅក្នុងពិធីសារចូលរួមអនុវត្តកិច្ចព្រមព្រៀងអាស៊ានដែលបានចុះហត្ថលេខា នៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៩

- បានឃើញលិខិតលេខ ១៤២ សហវ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៥ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការផ្ទេរផ្នែកទី ៤ ពីបញ្ជីដកចេញបណ្តោះអាសន្ន (Temporary Exclusion List) ទៅក្នុងបញ្ជីដាក់បញ្ចូល (Inclusion List) និង ការសំរេចរបស់ សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៧

## សំរេច

**ប្រការ១ :** ប្រកាសឱ្យប្រើប្រាស់កម្មវិធីកាត់បន្ថយអត្រាពន្ធគយដូចមានចែងលំអិតនៅក្នុងកម្មវិធីកាត់បន្ថយពន្ធគយនៃការផ្ទេរផ្នែកទី ៤ ពីបញ្ជីដកចេញបណ្តោះអាសន្ន តាមការសំរេចរបស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៧ លើការអនុវត្តន៍កិច្ចព្រមព្រៀង CEPT សំរាប់ AFTA ។

**ប្រការ២ :** ដើម្បីប្រសិទ្ធភាពនៃការអនុវត្តនីតិកាតព្វកិច្ចនានាដែលមាននៅក្នុងកិច្ចព្រមព្រៀង CEPT ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងចេញប្រកាសណែនាំជាបន្តបន្ទាប់ ។

**ប្រការ៣ :** ប្រកាសនេះ ចាប់មានប្រសិទ្ធភាពអនុវត្ត ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៦ តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៧

គាត ឈន់

ចម្លងជូន:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន ខេត្ត ក្រុង
  "ដើម្បីជូនជ្រាប"
- ទីចាត់ការគយ និងរដ្ឋាករ
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ